# សំណើលេខ 47

# ធ្វើឯកសារលើករណីនីមួយៗឡើងវិញ

**ខែមីនា ឆ្នាំ 2015**

**សំណើលេខ 47 ជាផ្លូវការហៅថាជា*ច្បាប់តំបន់និងសាលារៀនមានសុវត្ថិភាព* គឺជាច្បាប់មួយត្រូវបានអនុម័តដោយសារការផ្តើមគំនិតអ្នកបោះឆ្នោតនៅក្នុងរដ្ឋកាលីហ្វនីញ៉ា (California) កាលពីថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2014 ។ សំណើលេខ 47 នេះបានផ្លាស់ប្តូរបទឧក្រិដ្ឋតូចតាចខ្លះៗ ដូចជា មានថ្នាំញៀនជាប់ជាមួយ និងលួចរបស់តូចតាចកំប៉ិចកំប៉ុកតាមការប្រព្រឹត្តខុសលើបទឧក្រិដ្ឋ (ឬបទអាជ្ញា) រហូតទៅដល់បទល្មើសមជ្ឈឹម គិតបកទៅអតីតកាល និងអោយចម្រើនទៅមុខ ។ ការសន្សំប្រាក់ពីការចំណាយលើគុករបស់រដ្ឋ នឹងយកមកធ្វើវិនិយោគទុនជាថវិកា សំរាប់ជួយព្យាបាលអ្នកញៀនថ្នាំ និងសេវាសុខភាពខួរក្បាល សំរាប់ប្រជាជនក្នុងប្រព័ន្ធតុលាការឧក្រិដ្ឋកម្ម ក្នុងកម្មវិធីសំរាប់សិស្សស្ថិតក្នុងសភាពមានគ្រោះថ្នាក់នៅសាលារៀន ចាប់ពីថ្នាក់ទី K-12 នឹងសេវាកម្មសំរាប់ជនរងគ្រោះ ។**

---

**សំណើលេខ 47 នេះ មានការបះទង្គិចបីក្រុម ចំពោះមនុស្សណា ដែលបានប្រព្រឹត្តខុសមួយដងនៅក្នុងពេលនេះ ឬអ្នកធ្លាប់បានប្រព្រឹត្តខុសពីមុន ។[1]**

1, **ធ្វើឯកសារលើករណីនីមួយៗឡើងវិញ សំរាប់មនុស្សធ្លាប់ជាប់គុកក្នុងបទឧក្រិដ្ឋកម្មពីមុន ហើយមិនមានការគ្រប់គ្រងពីតុលាការ ។ (*ពាក្យសុំ*)**

2, **ដាក់ទោសសាថ្មីឡើងវិញសំរាប់មនុស្សណាកំពុងជាប់គុក ឬមនុស្សណាកំពុងមានបទឧក្រិដ្ឋកម្ម ហើយមានការគ្រប់គ្រងពីតុលាការ ។ (*លិខិតប្តឹង*)**

3, **ការកាត់ទោសសង្ឃឹមទៅអនាគត សំរាប់មនុស្សណាមានទោសតែមួយ ក្នុងបទឧក្រិដ្ឋទាំងនោះ ។**

---

**តើលោកអ្នកត្រូវការអ្វីខ្លះ ដើម្បីដាក់ពាក្យលើសំណើលេខ 47 ធ្វើករណីឡើងវិញនៅខោនធីឡូសអែនជើឡែស (Los Angeles County):**

1, លេខសំណុំរឿង

2, បទឧក្រិដ្ឋកម្ម: លេខកូដសម្ងាត់ ផ្នែក និងផ្នែករង (e.g. *11350 HS*)

3, ថ្ងៃខែ ជាប់ទោស

4, អាសយដ្ឋានតុលាការកាត់ទោស ។ វាត្រូវបានណែនាំ ថាលោកអ្នកទៅទីកន្លែងតុលាការណាដែលបានកាត់ទោសលោកអ្នក ព្រមទាំងដាក់ពាក្យទៅការិយាល័យមេធាវីតំបន់ និងអ្នកកាន់ក្រឡាបញ្ជីនៅឯតុលាការនោះផងដែរ ។

5, ក្រដាសដាក់ពាក្យដែលត្រូវការមានពីរ :

***ក, ក្រដាសដាក់ពាក្យ និងការប្តឹងតវ៉ា សំរាប់ដាក់ទោសសារថ្មីឡើងវិញ និង ក្រដាសឆ្លើយតប (PC §1170.18(a) និង (f))***

***ខ, ក្រដាសភស្តុតាងសេវា***

**បទឧក្រិដ្ឋខាងក្រោមនេះ អាចមានសិទ្ធិធ្វើឯកសារលើករណីនីមួយៗឡើងវិញ :**

| | |
|---|---|
| មានកាន់ជាប់ថ្នាំញៀនសាមញ្ញ | H.S. 11350, H.S. 11357, H.S. 11377 |
| លួចរបស់កំប៉ិកកំប៉ុកតម្លៃ $950 ឬតិចជាង | P.C. 666 |
| លួចឥវ៉ាន់តម្លៃ $950 ឬតិចជាង | P.C. 459 |
| ក្លែងបន្លំវត្ថុតម្លៃ $950 ឬតិចជាង | P.C. 470, P.C. 473 ( រួមបញ្ចូល PC 471,472, 475, 476, 484f និង 484(i(b) |
| សរសេរសែកក្លែងក្លាយតម្លៃ $950 ឬតិចជាង | P.C. 476(a) |
| បង្កាន់ដៃលួចយកទ្រព្យសម្បត្តិតម្លៃ $950 ឬតិចជាង | P.C. 496 |
| លួចប្លន់ តម្លៃ $950 ឬតិចជាង | P.C. 487, ( រួមបញ្ចូល PC 484e(a), 484e(a), 484e(b), 484e(d, 484g, 484h, 487a, 487b, 487d, 487h, 487i, 487j និង 489.) |

## អាចយកឯកសារបទឧក្រិដ្ឋកម្មរបស់លោកអ្នក:

1, ដើម្បីយកបញ្ជីបទឧក្រិដ្ឋរបស់លោកអ្នក នៅក្នុងបណ្តាញតំបន់អិលអេខោនធី (LA County) សូមចុចកន្លែងនេះ ឬមើលក្នុង "បណ្តាញមានប្រយោជន៍" នៅផ្នែកខាងក្រោមឯកសានោះ ។

- ក្នុងតារាងសៀវភៅ បង្ហាញតបមកវិញនូវបញ្ជីរាយលេខឯកសារ និងថ្ងៃខែបានបំពេញ ការជាប់ទាក់ទងក្រុមមនុស្ស ឬឈ្មោះក្រុមហ៊ុន ដែលលោកអ្នកបានដាក់ពាក្យទៅ ។ បើសិនជាមាន ការចោទប្រកាន់ កំពុងទទួលទោស កំពុងរៀបចំ និងថ្ងៃខែការរៀបចំ ត្រូវដាក់បញ្ចូលផងដែរ ។ *វែបសាយនេះមានព័ត៌មានថ្មីៗរៀងរាល់ថ្ងៃ ។* សូមចុចកន្លែងនេះដើម្បីមើលតាម គំរូស្រាវជ្រាវ ។ មានគិតប្រាក់ ១ ដុល្លារ សំរាប់ការស្រាវជ្រាវនេះ ។

2, នេះគឺជាតារាងបញ្ជីបន្ថែមទៀត ដែលជាវិធីសំរាប់ទទួលយកឯកសារបទឧក្រិដ្ឋរបស់លោកអ្នក សំរាប់តុលាការផ្សេងៗ (តាមតំបន់ ឬរដ្ឋ):

ក, តុលាការរបស់លោកអ្នកមានសំណុំរឿងកាត់ទោសលោកអ្នក ហើយអាចសុំយកសំណុំរឿងនោះ ពីកន្លែងតុលាការកាត់ទោសលោកអ្នកបាន ។ ពួកគេ អាចមានឯកសារដើម ក្នុងរឿងផ្តន្ទាទោសពីតុលាការ តែប៉ុណ្ណោះ ។

[1] សំរាប់គោលបំណងរបស់តុលាការ ប្រមូលផ្តុំដាក់ទៅក្នុងការ "ដាក់ពាក្យ" ឬ "លិខិតប្តឹង"

ខ. រដ្ឋកាលីហ្វញ៉ា ក្រសួងយុត្តិធម៌ និងឧក្រិដ្ឋកម្ម ផ្នែកខាងមើលសំណុំឯកសារឡើងវិញ ។ ពួកគេ អាចមានសំណុំឯកសាររឿងឧក្រិដ្ឋកម្មសំរាប់រដ្ឋកាលីហ្វញ៉ាទាំងមូល ។ សូមលោកអ្នកធ្វើអោយប្រាកដថា ធ្វើតាមការណែនាំសំរាប់ស្នើសុំឯកសារឧក្រិដ្ឋកម្មរបស់លោកអ្នកអោយបានត្រឹមត្រូវ ។ ដើម្បីស្នើសុំក្រដាសឯកសារចម្លងរឿងឧក្រិដ្ឋកម្មរបស់លោកអ្នក ក្នុងរដ្ឋកាលីហ្វញ៉ា សូមចុចកន្លែងនេះ ឬមើល "បណ្តាញមានប្រយោជន៏" នៅខាងក្រោម ។ លោកអ្នកអាចទាក់ទងទៅពួកគេតាមទូរស័ព្ទលេខ 916-227-3400 ។ មានគិតប្រាក់ថ្លៃឈ្នួល $25 ក្នុងការធ្វើ កិច្ចការនេះ ក៏ប៉ុន្តែ លោកអ្នកអាចមានសិទ្ធិទទួលការផាត់ចោលថ្លៃឈ្នួលនេះបាន ។ លោកអ្នកត្រូវផ្តល់ក្រដាសបញ្ជាក់ពីប្រាក់ចំណូលរបស់លោកអ្នក ។ ប្រហែលជា ប្រើពេលពីរបីអាទិត្យសំរាប់ផ្ញើឯកសារអោយបានទៅដល់តាមសំបុត្រ ។

គ. មេធាវីរបស់លោកអ្នក ភ្នាក់ងារមើលអ្នកទោសដោះលេង ភ្នាក់ងារមើលអ្នកទោសនៅក្រៅឃុំ ឬទាក់ទងនៅក្នុងសហគមន៏តុលាការ ឬការអនុវត្តច្បាប់ ។

**ផ្ញើឯកសារលើករណីនីមួយៗ ឡើងវិញ :**

1. **ការដាក់ពាក្យ/លិខិតប្តឹង សំរាប់ដាក់ទោសថ្មីសារឡើងវិញ ឆ្លើយតបមកពី(PC §1170.18(a) and (f),** ដើម្បីយក សូម ចុចកន្លែងនេះ ឬមើល "បណ្តាញមានប្រយោជន៏ " ។

ក. បើសិនជារូបអ្នកមិននៅជាប់គុកទៀត ព្រមទាំងមិនមានអ្នកមើលខុសត្រូវទេ លោកអ្នកត្រូវតែបំពេញក្រដាស់ដាក់ថា ជាអ្នកដាក់ពាក្យ តាមជម្រើសនៅលើក្រដាសបំពេញពាក្យនោះ ។

2. ដើម្បីយកក្រដាសភស្តុតាងទទួលសេវ៉ា សូម ចុចកន្លែងនេះ ឬមើល "បណ្តាញមានប្រយោជន៏"

ក. ក្រដាសភស្តុតាងទទួលសេវ៉ា ត្រូវដាក់ទៅតុលាការ ស្របគ្នានៅពេលលោកអ្នកដាក់លិខិតប្តឹង ឬដាក់ពាក្យ បញ្ជាក់នៅពេលណា ទីណា ដែលលោកអ្នកបានទទួលពីមេធាវីនៅក្នុងតំបន់ ។ គឺត្រូវតែផ្តល់អោយដោយអ្នកផ្សេងទៀត ដែលមិនមែនជារូបលោកអ្នក ម្យ៉ាងទៀតមនុស្សនោះត្រូវតែបំពេញ និងចុះហត្ថលេខាលើក្រដាសបញ្ជាក់ភស្តុតាងនៅពេលទទួលសេវ៉ានោះ ។

## ដំណើរការដាក់ពាក្យ:

នៅពេលលោកអ្នកមានក្រដាសបំពេញពាក្យទាំងពីរ និងព័ត៌មានបានមកពីឯកសារឧក្រិដ្ឋកម្មរបស់លោកអ្នកហើយ សូមបំពេញក្រដាសទាំងពីររបស់លោកអ្នក និងចុះហត្ថលេខានៅលើក្រដាសនោះ ។ នេះគឺជាសំណុំរឿងធ្វើករណីយ៍របស់អ្នកឡើងវិញ

ក. លោកអ្នកអាចដាក់ពាក្យធ្វើសំណុំករណីយ៍ឡើងវិញ ដោយឡែកផ្សេងៗពីគ្នា និងសំណុំរឿងមួយណា ដែលលោកអ្នកចង់ធ្វើសារថ្មីឡើងវិញ ។

ខ. សំរាប់សំណុំឯកសារនីមួយៗ លោកអ្នកត្រូវមានក្រដាសចម្លងបីក្នុងការធ្វើសំណុំករណីឡើងវិញ ។ ក្រដាសចម្លងដើម ត្រូវអោយទៅការិយាល័យតុលាការ ។ ក្រដាសចម្លងមួយទៀតអោយទៅមេធាវីតំបន់អិលអេ ។ ក្រដាសចម្លងមួយទៀត លោកអ្នកត្រូវទុកជាឯកសារសំរាប់ខ្លួនឯង ។

គ. នេះជាការណែនាំធ្វើសំណុំករណីនីមួយៗឡើងវិញ ត្រូវដាក់ទៅកន្លែងតុលាការណាដែលបានកាត់ទោសលោកអ្នក ។ នេះគឺជាបញ្ជីរាយឈ្មោះតុលាការកាត់ទោសឧក្រិដ្ឋកម្ម តុលាការកាត់ទោសឧក្រិដ្ឋកម្ម នៅតំបន់ឡូសអែនជើឡែសខោនធី ។[2]

[2] ទីកន្លែងតុលាការខ្លះបានបិទចោល ហើយប្តូរទៅទីកន្លែងផ្សេងៗដូចជា: ទីក្រុងណ័រវ៉ក គឺមើលខុសត្រូវលើក្រុងវិទីយ៉េ ចំណែកខាងវាលយន្តហោះ នឹងមើលខុសត្រូវលើក្រុងសាន់តាម៉ូនីកា ប៉ែលវើលីហ៊ៀល និងវែសអិលអេ ហើយក្រុងវ៉ាន់ណាយ នឹងមើលខុសត្រូវលើក្រុងម៉ាលីប៊ូ

ឃ. មិនតម្រូវអោយមានសវនាការទេ ក្នុងរឿងដាក់ពាក្យធ្វើករណីឡើងវិញ លុះត្រាតែមានសំណើពីខាងការិយាល័យមេធាវីតំបន់ ។ បើសិនជាអ្នកដាក់ពាក្យពេញចិត្តចំពោះសេចក្តីទាំងនោះ ហើយខាងតុលាការនឹងធ្វើកំណត់លើបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តខុស អោយក្លាយជាបទល្មើសតូចតាចវិញ ។

ង. ទាំងនេះ មិនមានការបង្ហាញពីតុលាការថា ត្រូវចំណាយពេលយូរប៉ុណ្ណា សំរាប់ទទួលដំណឹងនោះទេ ក៏ប៉ុន្តែ យើងសូមណែនាំ គួរតែដាក់ស្រោមសំបុត្រមួយមានឈ្មោះ និងអាសយដ្ឋាន ព្រមទាំងបិទតែមផង នេះអាចជាលទ្ធផលរហ័សមួយ ក្នុងការទាក់ទងមកពីខាងតុលាការ ។ តុលាការបានណែនាំសាធារណ:ជនថា លិខិតប្តឹងទាំងឡាយ គឺពិនិត្យមើលតាមការដាក់ពាក្យមុនគេ ។

**បណ្តាញមានប្រយោជន៏**

ស្វែងរកការិយាល័យសាធារណៈនៅតំបន់លោកអ្នក ខាងការពារអ្នកចុងចោទ
http://www.cpda.org/County/CountyPDWebSites.htm

ការិយាល័យសាធារណ:នៅតំបន់ខោនធីឡូសអែនជើឡែស ខាងការពារអ្នកចុងចោទ
http://pd.co.la.ca.us/

តំបន់ខោនធីឡូសអែនជើឡែស ការិយាល័យសាធារណ:ផ្លាស់ប្តូរការពារអ្នកចុងចោទ
ទីកន្លែង និង ព័ត៌មាន http://www.apd.lacounty.gov/Offices.htm &
http://www.apd.lacounty.gov/

អ្នកចុងចោទមានសិទ្ធិទទួល https://www.saccourt.ca.gov/criminal/docs/cr-pc-1170-18-petition-filing-information.pdf

ស្វាគមន៏សំណើលេខ 47
http://vig.cdn.sos.ca.gov/2014/general/pdf/text-ofproposed-laws1.pdf#prop47

ក្រដាសឆ្លើយតបសំរាប់ដាក់ពាក្យ និងលិខិតប្តឹង ដើម្បីធ្វើសំណុំករណីឡើងវិញ (PC §1170.18(a) and (f))
http://www.lacourt.org/forms/pdf/CRIM235.pdf

ក្រដាសភស្តុតាងទទួលសេវ៉ា http://www.lacourt.org/forms/pdf/CRIM237.pdf

សំរាប់ស្នើសុំក្រដាសប្រវត្តិឯកសារឧក្រិដ្ឋកម្មរបស់លោកអ្នក:
*http://oag.ca.gov/fingerprints/security*

សៀវភៅរាយឈ្មោះអ្នកចុងចោទ ក្នុងសំណុំរឿងឧក្រិដ្ឋកម្មនៅក្នុងតុលាការជាន់ខ្ពស់ឡូសអែនជើឡែស :
*https://www.lacourt.org/paonlineservices/criminalindex/publicmain.aspx?*

នេះគឺជាតារាងឈ្មោះកន្លែងតុលាការកាត់ក្តីរឿងឧក្រិដ្ឋកម្ម:
http://www.lacourt.org/courthouse/mode/division/criminal

តារាងឈ្មោះបទឧក្រិដ្ឋ ដែលមិនអាចអនុញ្ញាតដល់រូបលោកអ្នក ធ្វើការកែប្រែឯកសាររបស់លោកអ្នក ក្រោមសំណើលេខ 47:
http://www.sandiegocounty.gov/content/sdc/public_defender/Prop47Excludable.html